ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

# ស្តីពី

# ការសាកល្បងជ្រើសរើសជនទេសន្តរប្រវេសន៍ការងារខ្មែរ
# ទៅធ្វើការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងវិស័យសំណង់

យោងលិខិតការិយាល័យអនុព័ន្ធពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម លិខិតស្នើសុំរបស់ក្រុមហ៊ុនសំណង់ SONG DA 5 JOINT STOCK COMPANY និងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន ផេស៊ីហ្វិក អ៊ីមផ្លយម៉ិន អេជេន ឯ.ក (PACIFIC EMPLOYMENT AGENT CO., LTD.) និងក្រុមហ៊ុនសំណង់ SONG DA 5 JOINT STOCK COMPANY ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់បងប្អូនដែលមានបំណងទៅធ្វើការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងវិស័យសំណង់ ជ្រាបថា ក្រសួងបានអនុញ្ញាតឱ្យក្រុមហ៊ុន ផេស៊ីហ្វិក អ៊ីមផ្លយម៉ិន អេជេន ឯ.ក ដែលជាទីភ្នាក់ងារជ្រើសរើសឯកជនធ្វើការសាកល្បងក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងវិស័យសំណង់ នៅក្រុមហ៊ុនសំណង់ SONG DA 5 JOINT STOCK COMPANY។

## ក. លក្ខខណ្ឌជ្រើសរើស

- ភេទប្រុស មានអាយុចន្លោះពី ២៣ ដល់ ៣៩ឆ្នាំ
- មានចំណេះដឹងភាសាវៀតណាម ត្រូវបានផ្តល់អាទិភាព
- មានបទពិសោធន៍ការងារផ្នែកសំណង់
- មានកាយសម្បទារឹងមាំ និងស្មារតីល្អ អាចបំពេញការងារក្រោមបរិយាកាសក្តៅបាន
- មានកិរិយាមារយាទជាពលរដ្ឋល្អ មិនធ្លាប់ប្រើប្រាស់គ្រឿងញៀន ឬញៀនគ្រឿងស្រវឹង
- មិនមានប្រវត្តិប្រព្រឹត្តបទល្មើស ឬជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋ។

## ខ. ប្រភេទការងារ និងប្រាក់ខែ

- **ពលករទូទៅប្រើប្រាស់កម្លាំង** ទទួលបានប្រាក់ខែចំនួន ១៦លានដុង (ប្រមាណ ៦០០ដុល្លារអាម៉េរិក) ទៅចំនួន ២០លានដុង (ប្រមាណ ៧៦០ដុល្លារអាម៉េរិក)
- **ពលករជាងផ្សារ** ទទួលបានប្រាក់ខែចំនួន ២៥លានដុង (ប្រមាណ ៩៥០ដុល្លារអាម៉េរិក) ទៅចំនួន ៣០លានដុង (ប្រមាណ១ ១៤០ដុល្លារអាម៉េរិក)
- **ពលករជំនាញសំណង់ទូទៅ** ទទួលបានប្រាក់ខែចំនួន ២៥លានដុង (ប្រមាណ ៩៥០ដុល្លារអាម៉េរិក) ទៅចំនួន ៣០លានដុង (ប្រមាណ ១ ១៤០ដុល្លារអាម៉េរិក)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- **ពលករជំនាញបេតុង** ទទួលបានប្រាក់ខែចំនួន ២៥លានដុង (ប្រមាណ ៩៥០ដុល្លារអាម៉េរិក) ទៅចំនួន ៣០លានដុង (ប្រមាណ១ ១៤០ដុល្លារអាម៉េរិក)
- **ពលករបញ្ជាគ្រឿងចក្រ** ទទួលបានប្រាក់ខែចំនួន ២៥លានដុង (ប្រមាណ ៩៥០ដុល្លារអាម៉េរិក) ទៅចំនួន ៣០លានដុង (ប្រមាណ ១ ១៤០ដុល្លារអាម៉េរិក)
- **វិស្វករសំណង់ស៊ីវិល** ទទួលបានប្រាក់ខែចំនួន ២៨លានដុង (ប្រមាណ ១ ០៦០ដុល្លារអាម៉េរិក) ទៅចំនួន ៣៥លានដុង (ប្រមាណ ១ ៣៣០ដុល្លារអាម៉េរិក)។

**ទន្ទឹមនឹងនេះ ក្រុមហ៊ុននឹងទទួលរ៉ាប់រងលើមធ្យោបាយធ្វើដំណើរទៅមកពីប្រទេសកម្ពុជាទៅសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងផ្តល់កន្លែងស្នាក់នៅ ទឹក-ភ្លើង ដោយឥតគិតថ្លៃ និងឧបត្ថម្ភថ្លៃអាហារចំនួន ៥០% ផងដែរ។**

### គ. កាលបរិច្ឆេទ និងទីកន្លែងចុះឈ្មោះ

- កាលបរិច្ឆេទ៖ ទទួលចុះឈ្មោះចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- ទីកន្លែង៖ ក្រុមហ៊ុនផេស៊ីហ្វិក អ៊ីមផ្លយមិន អេជេន ឯ.ក
- អាសយដ្ឋាន៖ អគារលេខ៩២ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈក្រុមតេឡេក្រាម "**សម្រាប់ ពលករទេសន្តរប្រវេសន៍**" ឬតេឡេក្រាមរបស់ក្រុមហ៊ុនដែលមាន QR Code ខាងក្រោម ឬតាមរយៈទូរសព្ទលេខ ០១៦ ៧៧០ ៨៧០, ០៧៧ ៧៧០ ៨៧០, ០៦៦ ៧៧០ ៨៧០ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃអង្គារ ១៥រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦

លេខតេឡេក្រាមរបស់ក្រុមហ៊ុន

ក្រុមតេឡេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍"